# ឯកសារព័ត៌មាន

***Pro-democracy platform advocacy: Fostering social media's accountability to dissident voices under authoritarianism (ProPA)***

អ្នកត្រូវបានស្នើឱ្យចូលរួមក្នុងការសិក្សាលើប្រធានបទ "វេទិកាតស៊ូមតិគាំទ្រលទ្ធិប្រជាធិបតេយ្យ៖ **ជម្រុញគណនេយ្យភាពរបស់ប្រព័ន្ធបណ្តាញសង្គម ចំពោះសំឡេងប្រឆាំងនៅក្រោមអំណាចផ្តាច់ការ (ProPA)"** ។ ការចូលរួមរបស់អ្នកគឺស្ម័គ្រចិត្ត៖ អ្នកមិនមានកាតព្វកិច្ចក្នុងការចូលរួមទេ ហើយប្រសិនបើអ្នកបដិសេធ វានឹងមិនមានផលវិបាកអវិជ្ជមានអ្វីចំពោះអ្នកឡើយ។ សូមចំណាយពេលឲ្យបានគ្រប់គ្រាន់ដើម្បីសម្រេចចិត្តថាតើអ្នកចង់ចូលរួមឬអត់។ អ្នកក៏អាចសួរសំណួរមកកាន់អ្នកស្រាវជ្រាវបានគ្រប់ពេល ប្រសិនបើមានអ្វីមួយមិនច្បាស់លាស់។ អ្នកអាចបញ្ឈប់ការចូលរួមរបស់អ្នកនៅពេលណាក៏បាន (ជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់) ហើយអ្នកមិនត្រូវបានតម្រូវឲ្យផ្តល់ហេតុផលក្នុងការធ្វើដូច្នេះទេ។

ខាងក្រោមនេះ អ្នកអាចស្វែងរកព័ត៌មានបន្ថែមអំពីការសិក្សា និងពីរបៀបដែលវានឹងដំណើរការ។ ប្រសិនបើអ្នកត្រូវការព័ត៌មានបន្ថែម អ្នកអាចទាក់ទងមកកាន់អ្នកស្រាវជ្រាវ ឬអ្នកគ្រប់គ្រងរបស់គាត់បានគ្រប់ពេល។

<u>ព័ត៌មានសម្រាប់ទំនាក់ទំនង</u>

**Mai Van Tran**
Brussels School of Governance, CD2I
Vrije Universiteit Brussel (VUB)
អ៊ីមែល៖ mai.van.tran@vub.be
លេខទូរស័ព្ទ: [redacted]

**Trisha Meyer**
Brussels School of Governance, CD2I
Vrije Universiteit Brussel (VUB)
អ៊ីមែល៖ trisha.meyer@vub.be
លេខទូរស័ព្ទ: +3226148001

---

ការស្រាវជ្រាវនេះ គឺជាផ្នែកមួយនៃអាហារូបករណ៍ក្រោយថ្នាក់បណ្ឌិត ដែលផ្តល់មូលនិធិដោយសហភាពអឺរ៉ុប។ គោលដៅចម្បងនៃការស្រាវជ្រាវនេះ គឺដើម្បីពិនិត្យមើលដំណើរកិច្ចខិតខំប្រឹងប្រែងតស៊ូមតិ លើការសម្របសម្រួលមាតិការបស់វេទិកាបណ្តាញសង្គម នៅក្នុងប្រទេសមីយ៉ាន់ម៉ា ថៃ និងកម្ពុជា។ សំណួរស្រាវជ្រាវខាងក្រោម នឹងត្រូវបានដោះស្រាយ៖ តើការខិតខំប្រឹងប្រែងតស៊ូមតិបាននាំឱ្យមានការផ្លាស់ប្តូរក្នុងការអនុវត្តការសម្របសម្រួលមាតិការបស់វេទិកាឌីជីថលដល់កម្រិតណា? ការស្រាវជ្រាវនឹងផលិតទាំងការ បោះពុម្ពផ្សាយផ្នែកសិក្សា និងគោលនយោបាយ។

អ្នកចូលរួម គឺជាសកម្មជនសិទ្ធិឌីជីថល និងសកម្មជនគាំទ្រលទ្ធិប្រជាធិបតេយ្យផ្សេងទៀត ដែលជាសហគមន៍មកពីប្រទេសមីយ៉ាន់ម៉ា ថៃ និងកម្ពុជា មានភាពសកម្មក្នុងបញ្ហានយោបាយនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម។

ការសម្ភាសន៍នឹងត្រូវបានធ្វើឡើងទាំងដោយផ្ទាល់ ក្នុងបរិយាកាសអព្យាក្រឹត ដែលផ្តល់នូវឯកជនភាពគ្រប់គ្រាន់សម្រាប់អ្នកចូលរួម ឬតាមរយៈបណ្តាញទំនាក់ទំនងដែលមានកូដនីយកម្ម។

**ឯកសារព័ត៌មាន**

ឯកសារព័ត៌មាននឹងត្រូវបានផ្ញើទៅអ្នកចូលរួមមួយ ឬពីរថ្ងៃ មុនពេលសម្ភាសន៍។ មុនពេលកិច្ចសម្ភាសន៍នីមួយៗចាប់ផ្តើម អ្នកស្រាវជ្រាវនឹងសួរថា តើអ្នកចូលរួមយល់ព្រមក្នុងការផ្តល់បទសម្ភាសន៍ក្នុងការស្រាវជ្រាវដែរឬទេ បន្ទាប់មកអ្នកស្រាវជ្រាវនឹងរក្សាការកត់ត្រាពីការយល់ព្រមជាសំឡេង របស់អ្នកចូលរួមដូចតទៅ៖ "ខ្ញុំបានទទួលច្បាប់ចម្លងនៃឯកសារព័ត៌មាន ដែលមានហត្ថលេខារបស់អ្នកស្រាវជ្រាវ។ ខ្ញុំយល់ព្រមចូលរួមក្នុងការស្រាវជ្រាវនេះ និងដំណើរការនៃទិន្នន័យផ្ទាល់ខ្លួនរបស់ខ្ញុំ សម្រាប់ការបោះពុម្ពផ្សាយស្រាវជ្រាវបែបវិទ្យាសាស្ត្រ។ ខ្ញុំផ្តល់ការអនុញ្ញាតឱ្យដកស្រង់ពាក្យសម្តីជាលក្ខណៈអនាមិក។ ឈ្មោះរបស់ខ្ញុំ នឹងមិនត្រូវបានបោះពុម្ពផ្សាយឡើយ ហើយការសម្ងាត់នៃទិន្នន័យត្រូវបានធានាក្នុងអំឡុងពេលស្រាវជ្រាវ។" ប្រសិនបើអ្នកចូលរួម យល់ព្រមឱ្យមានការថតសំឡេងសម្ភាសន៍ ការយល់ព្រមដោយពាក្យសំដីរបស់ពួកគេ នឹងរួមបញ្ចូលដូចតទៅ៖ "ខ្ញុំយល់ព្រមឱ្យថតសំឡេងសម្ភាសន៍របស់ខ្ញុំ"។ ប្រសិនបើអ្នកចូលរួមយល់ព្រមឱ្យមានវត្តមានអ្នកបកប្រែក្នុងពេលសម្ភាសន៍ ការយល់ព្រមដោយពាក្យសំដីក៏នឹងរួមបញ្ចូលដូចតទៅផងដែរ៖ "ខ្ញុំយល់ព្រម ចំពោះការចូលរួមរបស់អ្នកបកប្រែនៅក្នុងការសម្ភាសន៍របស់ខ្ញុំ"។

ការថតសំឡេងនឹងត្រូវបានអនុវត្ត ដើម្បីកត់ត្រាការឆ្លើយតបរបស់អ្នកចូលរួម ឱ្យបានត្រឹមត្រូវសម្រាប់ការវិភាគនៅពេលក្រោយ។ អ្នកចូលរួមអាចបដិសេធការថតសំឡេង ដោយមិនត្រូវបានដកចេញពីការស្រាវជ្រាវឡើយ។

ការសម្ភាសន៍នីមួយៗអាចមានរយៈពេលប្រហែល ១ ម៉ោង ទៅ ១.៥ ម៉ោង។

អ្នកស្រាវជ្រាវ នឹងធានាថាអត្តសញ្ញាណរបស់អ្នកចូលរួម មិនត្រូវបានលាតត្រដាងតាមរយៈឯកសារស្រាវជ្រាវ ឬការបោះពុម្ពផ្សាយឡើយ។ អ្នកស្រាវជ្រាវនឹងមិនកត់ត្រាអត្តសញ្ញាណផ្ទាល់ខ្លួនរបស់អ្នកចូលរួម (ដូចជា ឈ្មោះ អាយុ ភេទ អត្តសញ្ញាណជនជាតិ/សាសនា ឈ្មោះអង្គការ)។ ការទំនាក់ទំនងណាមួយរវាងអ្នកស្រាវជ្រាវ និងអ្នកចូលរួមនឹងធ្វើឡើងតាមរយៈបណ្តាញទំនាក់ទំនងដែលមានកូដនីយកម្ម។

បន្ទាប់ពីការសម្ភាសន៍នីមួយៗ អ្នកចូលរួមមានសិទ្ធិពិនិត្យមើលឡើងវិញ ពីប្រតិចារិកសំភាសន៍របស់ពួកគេ ដើម្បីលុបផ្នែកដែលគាត់មិនចង់បាន។

តាមរយៈការស្រាវជ្រាវ អ្នកចូលរួមនឹងទទួលបានចំណេះដឹង និងការយល់ដឹងកាន់តែប្រសើរឡើងអំពីវេទិកាតស៊ូមតិពីតំបន់អាស៊ីអាគ្នេយ៍ ឆ្ពោះទៅរកក្រុមហ៊ុនបច្ចេកវិទ្យាធំៗ លើការសម្របសម្រួលមាតិកានយោបាយ។ អ្នកស្រាវជ្រាវនឹងចែករំលែកលទ្ធផលស្រាវជ្រាវជាមួយអ្នកចូលរួម។

ការរកឃើញនៃការស្រាវជ្រាវក៏នឹងជូនដំណឹងដល់សកម្មជន អំពីយុទ្ធសាស្រ្តតស៊ូមតិប្រកបដោយប្រសិទ្ធភាព ដែលពួកគេអាចដាក់បញ្ចូលនៅក្នុងយុទ្ធនាការតស៊ូមតិរបស់ពួកគេ។ *ផលប៉ះពាល់រួមនឹងបណ្តាលឱ្យមានបរិយាកាសឌីជីថល* ***ដែលមានសុវត្ថិភាព*** *និង* ***បរិយាបន្ន****កាន់តែច្រើន ក្នុងរយៈពេលវែង។*

# ឯកសារព័ត៌មាន

## ឯកជនភាព និងការសម្ងាត់

ក្នុងនាមជាអ្នកស្រាវជ្រាវ ខ្ញុំមានកាតព្វកិច្ច រក្សាការសម្ងាត់ទាក់ទងនឹងទិន្នន័យដែលប្រមូលបាន។ នេះមានន័យថា ខ្ញុំមិនបង្ហាញឈ្មោះ ឬទិន្នន័យផ្សេងទៀតរបស់អ្នក ដែលអាចកំណត់អត្តសញ្ញាណអ្នកបានទេ ឧទាហរណ៍នៅក្នុងបរិបទនៃការបោះពុម្ពផ្សាយ ឬសន្និសីទណាមួយ។ លទ្ធផលបុគ្គលក៏នឹងមិនត្រូវបាន បោះផ្សាយដែរ។

នៅក្នុងគម្រោងស្រាវជ្រាវនេះ ទិន្នន័យផ្ទាល់ខ្លួននឹងត្រូវបានប្រមូលពីអ្នក។ ការប្រមូល និងដំណើរការ នៃទិន្នន័យរបស់អ្នក អាចធ្វើទៅបាន ដោយសារខ្ញុំធ្វើការស្រាវជ្រាវបែបវិទ្យាសាស្ត្រ ហើយខ្ញុំទទួលបានការព្រម ព្រៀងពីអ្នក ។

ការប្រមូល និងដំណើរការទិន្នន័យ គឺអនុលោមតាមគោលការណ៍ច្បាប់ដែលកំណត់ដោយ បទប្បញ្ញត្តិ ការការពារទិន្នន័យទូទៅ របស់សហភាពអឺរ៉ុប (GDPR) ដែលចូលជាធរមាននៅថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ២០១៨។ ខ្ញុំ Mai Van Tran មានកាតព្វកិច្ចគ្រប់គ្រងភាពត្រឹមត្រូវនៃដំណើរការទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក និងព័ត៌មានដែលពាក់ព័ន្ធផ្សេងទៀត។

កាតព្វកិច្ចក្នុងការផ្តល់ព័ត៌មាននេះ មានន័យថាខ្ញុំត្រូវតែជូនដំណឹងដល់អ្នកអំពីព័ត៌មានដូចតទៅ៖

a. ទិន្នន័យផ្ទាល់ខ្លួនដែលខ្ញុំប្រមូលពីអ្នក ជាក់ស្តែងដូចជា៖ ការថតសំឡេង (ជាជម្រើស) ការងាររបស់ស្ថាប័នអ្នក និងប្រភេទនៃអ្នកពាក់ព័ន្ធបទពិសោធន៍របស់អ្នកពាក់ព័ន្ធជាមួយសកម្មភាពប្រព័ន្ធបណ្តាញសង្គម និងការចូលរួមតស៊ូមតិរបស់ស្ថាប័នអ្នកជាមួយក្រុមហ៊ុនប្រព័ន្ធបណ្តាញសង្គម។

b. VUB (Vrije Universiteit Brussel, Pleinlaan 2, 1050 Brussel, KBO 449.012.406) ដើរតួជាអ្នកគ្រប់គ្រងទិន្នន័យរបស់អ្នក។

c. ទិន្នន័យត្រូវបានប្រមូល និងដំណើរការសម្រាប់គោលបំណងនៃការសិក្សាដែលបានរៀបរាប់ខាងលើ។ ស្របតាមច្បាប់ដែលពាក់ព័ន្ធ ហើយទិន្នន័យដែលប្រមូលបាន ជាផ្នែកនៃការសិក្សានឹងត្រូវបានរក្សាទុកក្នុងរយៈពេល ៥ ឆ្នាំ។

d. ខ្ញុំអាចប្រើទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក សម្រាប់គោលបំណងស្រាវជ្រាវវិទ្យាសាស្ត្រតែប៉ុណ្ណោះ។

e. អ្នកមានសិទ្ធិចូលប្រើ និងកែតម្រូវទិន្នន័យរបស់អ្នក។ អ្នកក៏មានសិទ្ធិក្នុងការ លុបទិន្នន័យរបស់អ្នក កំណត់ព្រំដែនដំណើរការរបស់វា ជំទាស់នឹងដំណើរការរបស់វា និងផ្ទេរទិន្នន័យរបស់អ្នកទៅភាគីទីបី។ ប្រសិនបើអ្នកមានសំណួរ សូមទាក់ទងអ្នកស្រាវជ្រាវ និង/ឬអ្នកគ្រប់គ្រងរបស់គាត់។

f. អ្នកមានសិទ្ធិដកការយល់ព្រមរបស់អ្នក ចំពោះដំណើរការនៃទិន្នន័យរបស់អ្នកគ្រប់ពេល។ ការដកការយល់ព្រម មិនប៉ះពាល់ដល់ភាពស្របច្បាប់ នៃដំណើរការទិន្នន័យដែលទទួលបានមុនការ ដកការយល់ព្រមនោះទេ។

g. ព័ត៌មានផ្ទាល់ខ្លួនលម្អិតរបស់អ្នក នឹងត្រូវបានពិនិត្យមើលដោយអ្នកស្រាវជ្រាវ ដែលត្រូវបានតែងតាំងខាងលើប៉ុណ្ណោះ ហើយនឹងមិនត្រូវបានចែករំលែកជាមួយស្ថាប័នផ្សេងទៀតឡើយ។

h. ទិន្នន័យរបស់អ្នកនឹងត្រូវបានរក្សាទុក និងធានាដោយអនុលោមតាមការណែនាំរបស់ VUB ។

i. ប្រសិនបើអ្នកមានបំណងចង់អនុវត្តសិទ្ធិរបស់អ្នក ឬប្រសិនបើអ្នកមានសំណួរបន្ថែមទាក់ទងនឹងសិទ្ធិរបស់អ្នក និងដំណើរការនៃទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក អ្នកអាចទាក់ទងមន្ត្រី ការពារទិន្នន័យ VUB ជានិច្ចតាមរយៈ៖ dpo@vub.be ។

j. ដើម្បីធានាឯកជនភាពរបស់អ្នក វិធានការការពារខាងក្រោមនឹងត្រូវធ្វើឡើង៖

- ទិន្នន័យដែលប្រមូលបាន គឺមិនមានភាពអនាមិកឡើយក្នុងដំណាក់កាលទី1 ដែលជាមូលហេតុទិន្នន័យទាំងនោះនឹងត្រូវបានបំប្លែងទៅជាកូដ (ក្លែងបន្លំ) ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ កូដនេះគឺជាសំណុំទិន្នន័យទី ២ ដែលត្រូវបានបង្កើតឡើង ដែលវាមិនអាចកំណត់អត្តសញ្ញាណអ្នកដោយផ្ទាល់បានទៀតទេ។ ដូច្នេះ "គន្លឹះក្នុងការបកប្រែ" ត្រូវបានបង្កើតឡើង ដែលអាចបំឡែងកូដទៅជាអត្ថន័យដើមរបស់វា។ មានតែអ្នកស្រាវជ្រាវ Mai Van Tran ប៉ុណ្ណោះ ដែលមានសិទ្ធិប្រើប្រាស់កូនសោ ចូលទៅកាន់ទិន្នន័យដើម។ នេះធានាបានថា មានតែអ្នកស្រាវជ្រាវម្នាក់ប៉ុណ្ណោះ ដែលអាចភ្ជាប់ទិន្នន័យនេះទៅកាន់អ្នកបាន។ សោកូដន័យកម្មត្រូវបានរក្សាទុក ដោយឡែក និងយ៉ាងមានសុវត្ថិភាព។

- ការថតសំឡេងដែលបានធ្វើឡើងអំឡុងពេលសម្ភាសន៍នឹងត្រូវបានបំប្លែងទៅជាប្រតិចារិកឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន បន្ទាប់មកការថតសំឡេងនឹងត្រូវបានលុប។

- ទិន្នន័យរបស់អ្នកនឹងត្រូវបានរក្សាទុកតែនៅលើ [redacted]ប៉ុណ្ណោះ។ វាមានលក្ខខណ្ឌក្នុងការចូលប្រើយ៉ាងតឹងរ៉ឹង និងផ្តល់នូវការការពារកម្រិតខ្ពស់។ ដូច្នេះទិន្នន័យរបស់អ្នកមិនត្រូវបានរក្សាទុកនៅលើកុំព្យូទ័រផ្ទាល់ខ្លួន ឬនៅលើ USB (លើកលែងតែពេលដែលទិន្នន័យ ត្រូវបានធ្វើកូដន័យកម្មនៅលើ USB) របស់អ្នកស្រាវជ្រាវ ហើយមិន ត្រូវបានបញ្ជូនបន្តតាមអ៊ីមែលឡើយ។

k. ចុងក្រោយ អ្នកក៏មានសិទ្ធិប្តឹងតវ៉ា អំពីរបៀបដែលទិន្នន័យរបស់អ្នកកំពុងត្រូវបានគ្រប់គ្រង។ អ្នកអាចធ្វើដូចនេះជាមួយអាជ្ញាធរត្រួតពិនិត្យរបស់ប្រទេសបែលហ្ស៊ិក ដែលទទួលខុសត្រូវក្នុងការអនុវត្តច្បាប់ការពារទិន្នន័យ ជាក់ស្តែង៖
Gegevensbeschermingsautoriteit (GBA)

VRIJE UNIVERSITEIT BRUSSEL

## ឯកសារព័ត៌មាន


Drukpersstraat 35
1000 Brussel
ទូរស័ព្ទ៖ +32 2 274 48 00
អ៊ីមែល៖ contact@apd-gba.be
គេហៈទំព័រ៖ www.gegevensbeschermingsautoriteit.be


I. ក្នុងករណីអ្នកមានឧបសគ្គភាសា ក្នុងការទំនាក់ទាក់ទងជាមួយ DPO ឬ GBA អ្នកអាចទទួលបានការគាំទ្រការបកប្រែ ពីមូលនិធិ [redacted] ដែលជាមជ្ឈមណ្ឌលបច្ចេកវិទ្យាសហគមន៍មិនរកប្រាក់ចំណេញ តាមរយៈ [redacted]។

## សេចក្តីថ្លែងការណ៍របស់អ្នកស្រាវជ្រាវ

ខ្ញុំអ្នកស្រាវជ្រាវ ត្រាន់ ម៉ៃ វ៉ាន់ អះអាងថា ខ្ញុំបានផ្តល់ព័ត៌មានចាំបាច់អំពីការសិក្សានេះ ដោយផ្ទាល់មាត់ក៏ដូចជាច្បាប់ចម្លងជាលាយលក្ខណ៍អក្សរ ដល់អ្នកចូលរួម។

ខ្ញុំសូមបញ្ជាក់ថា គ្មានសម្ពាធណាមួយត្រូវបានបង្ខំមកលើអ្នកចូលរួម ដើម្បីឱ្យគាត់យល់ព្រមចូលរួមក្នុងការសិក្សានោះទេ ហើយខ្ញុំស្ម័គ្រចិត្តឆ្លើយសំណួរបន្ថែមផ្សេងទៀតប្រសិនបើមាន។

ខ្ញុំសូមបញ្ជាក់ថា ខ្ញុំធ្វើការស្របតាមគោលការណ៍សីលធម៌ ដូចមានចែងនៅក្នុង "ក្រមសម្រាប់ការស្រាវជ្រាវបែបវិទ្យាសាស្ត្រនៅប្រទេសបែលហ្សិក" និងគោលការណ៍សីលធម៌នៅក្នុងវិន័យស្រាវជ្រាវរបស់ខ្ញុំ។

ខ្ញុំសូមបញ្ជាក់ថា ខ្ញុំធ្វើការដោយអនុលោមតាមកាតព្វកិច្ចផ្លូវច្បាប់ ទាក់ទងនឹងដំណើរការត្រឹមត្រូវ នៃទិន្នន័យផ្ទាល់ខ្លួន ដែលមានចែងក្នុងបទប្បញ្ញត្តិការពារទិន្នន័យទូទៅ (GDPR)។

---

ឈ្មោះ នាមខ្លួន កាលបរិច្ឆេទ និងហត្ថលេខារបស់អ្នកស្រាវជ្រាវ

9/1/2024
Tran Mai Van